**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍បាត់ដំបង**

សំណុំរឿងសភាព្រហ្មទណ្ឌលេខ ២៦៥
ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២
**សាលដីកា**
លេខ ៥៥០ "ជ"
ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍បាត់ដំបង

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលបានប្រកាសឲ្យប្រើតាម ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍បាត់ដំបង នាថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ ដោយមានសមាសភាពដូចខាងក្រោម ៖

17-10-22
[illegible]

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាឧទ្ធរណ៍

ដើម្បីជំនុំជម្រះបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងសភាព្រហ្មទណ្ឌលេខ ២៦៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ មានដូចខាងក្រោម ៖

**-ជនជាប់ចោទមាន៖**

១.ឈ្មោះ [redacted] ហ៊ាន ភេទប្រុស អាយុ ៥៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមេភូមិចារ ទីកន្លែងកំណើតនៅភូមិគោកក្រូច ឃុំសំបួរ ស្រុកក្រឡាញ់ ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្នទៅភូមិចារ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៥នាក់ ឪពុកឈ្មោះ [redacted] (ស)



Scanned with CamScanner

ម្តាយឈ្មោះ [redacted] (ស) កម្រិតវប្បធម៌ថ្នាក់ទី០៨(ចាស់) ទោសពីមុន "គ្មាន"។ (ក្រៅឃុំ) (មិនប្តឹងឧទ្ធរណ៍)

+ដោយមានលោកស្រី [redacted] នីតិយ៉ាណា អគ្គលេខ ១៥២៣ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

២.ឈ្មោះ [redacted] ប៊ុស្ស ភេទប្រុស អាយុ ៥៦ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិខាងស ឃុំគោល ស្រុកអង្គរជុំ ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិចារ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ប្រពន្ធឈ្មោះ [redacted] ជួប មានកូនចំនួន ០៥នាក់ ឪពុកឈ្មោះ [redacted] យ៉េន (ស) ម្តាយឈ្មោះ [redacted] (រ) កម្រិតវប្បធម៌មិនចេះអក្សរ ទោសពីមុន "គ្មាន"។ (ក្រៅឃុំ) (មិនប្តឹងឧទ្ធរណ៍)

+ដោយមានលោកស្រី [redacted] នីតិយ៉ាណា អគ្គលេខ ១៥២៣ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

៣.ឈ្មោះ [redacted] ចិត្ត ហៅ ចត ភេទប្រុស អាយុ ២១ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិសំបួរ ឃុំនគរភៀស ស្រុកអង្គរជុំ ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិចារថ្មី ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នៅលីវ ឪពុកឈ្មេ[redacted] (ស) ម្តាយឈ្មោះ [redacted] (រ) កម្រិតវប្បធម៌ថ្នាក់ទី០៥ ទោសពីមុន "គ្មាន"។ (ក្រៅឃុំ) (មិនប្តឹងឧទ្ធរណ៍)

៤.ឈ្មោះ [redacted] ឈួន ភេទប្រុស អាយុ ២៧ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិត្រាំសារ ឃុំត្រាំសារ ស្រុកក្រាំសារ ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិចារថ្មី ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០១នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ ផឹង (ស) កម្រិតវប្បធម៌ថ្នាក់ទី០១ ទោសពីមុន "គ្មាន"។ (ក្រៅឃុំ) (មិនប្តឹងឧទ្ធរណ៍)

៥.ឈ្មោះ [redacted] សារឿន ភេទប្រុស អាយុ ២៦ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិយាយម៉ី ឃុំជ្រោយនាងងួន ស្រុកស្រីស្នំ ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិអាគោ ឃុំចុងកាល់ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ ប្រពន្ធឈ្មោ[redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុន "គ្មាន"។ (ក្រៅឃុំ) (មិនប្តឹងឧទ្ធរណ៍)

៦.ឈ្មោះ[redacted] កេន ភេទប្រុស អាយុ ៤៣ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិសំបួរ ឃុំនគរភៀស ស្រុកថ្មពួក ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិចារ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៦នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ ភាព។ (ក្រៅឃុំ) (មិនប្តឹងឧទ្ធរណ៍)

៧.ឈ្មោ[redacted]ធន ភេទប្រុស អាយុ ២៣ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិចារថ្មី ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (ក្រៅឃុំ) (មិនប្តឹងឧទ្ធរណ៍)

ជាប់ចោទពីបទ: ប៉ុនប៉ងឃាតកម្ម និងហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិចារថ្មី ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ១៩៩ និងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

-ដើមបណ្ដឹងរដ្ឋប្បវេណីមាន៖

១.ឈ្មោះ[redacted]ឈាន ភេទប្រុស អាយុ ២៣ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិរមៀត ឃុំស្ពែងស្ពាន ស្រុកស្រីស្នំ ខេត្តឧត្តរមានជ័យ ។

២.ឈ្មោះ[redacted] អាយ ភេទប្រុស អាយុ ១៩ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិរមៀត ឃុំស្ពែងស្ពាន ស្រុកស្រីស្នំ ខេត្តឧត្តរមានជ័យ ។

៣.ឈ្មោះ[redacted] សៅរ៍ ភេទប្រុស អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិរមៀត ឃុំស្ពែងស្ពាន ស្រុកស្រីស្នំ ខេត្តឧត្តរមានជ័យ ។

៤.ឈ្មោះ[redacted]ខ្មៅ ភេទប្រុស អាយុ ២០ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិរមៀត ឃុំស្ពែងស្ពាន ស្រុកស្រីស្នំ ខេត្តឧត្តរមានជ័យ ។

## អំពីអង្គហេតុ

កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង ០៤ និង ៣០នាទីរសៀល នៅភូមិចារថ្មី ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មានករណី ប៉ុនប៉ងឃាតកម្ម និងហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសមួយកើតឡើង ដែលបង្កឡើងដោយជនជាប់សង្ស័យ ១.ឈ្មោះ[redacted]ហ៊ាន ភេទប្រុស អាយុ ៥៥ឆ្នាំ ២.ឈ្មោះ [redacted]បុស្ស ភេទប្រុស អាយុ ៥៦ឆ្នាំ ៣.ឈ្មោះ[redacted] ចិត្ត ភេទប្រុស អាយុ ២១ឆ្នាំ ៤.ឈ្មោះ[redacted]យួន ភេទប្រុស អាយុ ២៧ឆ្នាំ ៥.ឈ្មោះ[redacted]ភេន ភេទប្រុស អាយុ ៤៥ឆ្នាំ ៦.ឈ្មោះ [redacted] រឿន ភេទប្រុស អាយុ ២៥ឆ្នាំ ៧.ឈ្មោះ[redacted] ធន ភេទប្រុស អាយុ ២៣ឆ្នាំ និង៨.ឈ្មោះ បក្សពួក(ច្រើននាក់) បានធ្វើសកម្មភាពយករថយន្តនិងគោយន្តដាក់ទទឹងផ្លូវ ដោយមានកាន់ដំបង កាន់ពូថៅ កាន់ញញួរ និងជំនីក និងកាំបិទ បាននាំគ្នាព្រួតវាយទៅលើជនរងគ្រោះឈ្មោះ [redacted] ឈាន ភេទប្រុស អាយុ ២៣ឆ្នាំ បណ្ដាលឱ្យរបួលត្រង់ស្មារខាងស្ដាំចំនួន ០១កាំបិទ កែងដៃឆ្វេងចំនួន ០៣ដំបង និងជាំចង្កេះខាងក្រោយផ្នែកខាងស្ដាំ និងត្រូវចំត្រចៀកខាងឆ្វេងផុះពីក្រោយទៅមុខ ចំនួន ០១កាំបិត ត្រូវចំគុម្ពត្រចៀកខាងស្ដាំ ។ ចំណែកជនរងគ្រោះឈ្មោះ [redacted]អាយ ភេទប្រុស អាយុ ១៨ឆ្នាំ រងរបួសត្រង់ជើងខាងឆ្វេងវាយចំក និងរបួសពេញខ្លួនរហូតដល់សន្លប់ និងជនរងគ្រោះឈ្មោះ [redacted]សៅរ៍ ភេទប្រុស អាយុ ១៨ឆ្នាំ របួសនៅត្រង់ដៃខាងស្ដាំ និង កញ្ចឹងក និងជនរងគ្រោះឈ្មោះ[redacted] ខ្មៅ ភេទប្រុស អាយុ ២០ឆ្នាំ ត្រូវរបួសដៃខាងស្ដាំចំនួន ០១កាំបិត ស្រាំឆ្អឹង និង ត្រូវចំខ្នងចំនួនប្រហែល ០៥ដំបង ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១០ (ក)/១៥ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ដែលបានសម្រេច៖

១.ឱ្យជនជាប់ចោទឈ្មោះ[redacted] ហាន ភេទប្រុស អាយុ ៥៥ឆ្នាំ និងឈ្មោះ[redacted]បុស្ស ភេទប្រុស អាយុ ៥៦ឆ្នាំ (មានសាវតាជាតិដូចខាងលើ បានរួចផុតពីបទចោទប្រកាន់ ពីបទ ប៉ុនប៉ងឃាតកម្ម និងហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិចារថ្មី ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមាន



Scanned with CamScanner

ជ័យ កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ មាត្រា ១៩៩ និងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

**ខ.ផ្តន្ទាទោស**

ក.ឈ្មោះ [redacted] ចិត្ត ហៅ ចត ភេទប្រុស អាយុ ២១ឆ្នាំ (មានសាវតាជាតិដូចខាងលើ)

ខ.ឈ្មោះ [redacted] ឈ្នួន ភេទប្រុស អាយុ ២៧ឆ្នាំ (មានសាវតាជាតិដូចខាងលើ)

គ.ឈ្មោះ [redacted] សារឿន ភេទប្រុស អាយុ ២៦ឆ្នាំ (មានសាវតាជាតិដូចខាងលើ)

ឃ.ឈ្មោះ [redacted] កេន ភេទប្រុស អាយុ ៤៣ឆ្នាំ (មានសាវតាជាតិដូចខាងលើ)

ង.ឈ្មោះ [redacted] ធន ភេទប្រុស អាយុ ២៣ឆ្នាំ (មានសាវតាជាតិដូចខាងលើ)

ដាក់ពន្ធនាគារកំណត់រយៈពេល ០៧ (ប្រាំពីរ)ឆ្នាំ ពីបទ ប៉ុនប៉ងឃាតកម្ម និងហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិចារថ្មី ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ មាត្រា ១៩៩ និងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈថ្ងៃពុធ ១០កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ប៊ាន, [redacted] បុស្ស, [redacted] ចិត្ត, [redacted] ឈ្នួន [redacted] សារឿន, [redacted] កេន, [redacted] ធន និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហាន, [redacted] អាយ. [redacted] សៅរ៍ និងឈ្មោះ [redacted] ខ្មៅ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ របស់ តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ បានប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១០ (ក)/១៥ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ត្រង់ចំណុចសេចក្តីសម្រេចឱ្យឈ្មោះ [redacted] ប៊ាន និងឈ្មោះ [redacted] បុស្ស ឱ្យរួចផុតពីបទចោទប្រកាន់ នៅក្នុងសាលក្រមព្រហ្មទណ្ឌខាងលើ ។

-បានឃើញ ដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះលេខ ២៧៧ ព្រទ.ឧបប/២២ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង ។

-បានឃើញ របាយការណ៍រឿងសភាព្រហ្មទណ្ឌ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ ។

-បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ របស់មហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ។

**នាពេលសវនាការ**

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] ហ៊ាន បានឆ្លើយថា៖ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ហើយខ្លួនសូមបញ្ជាក់ថា ខ្លួនមិនបានស្គាល់ក្មេងរងគ្រោះទាំងអស់នេះទេ ប៉ុន្តែខ្លួនធ្លាប់ស្គាល់ឪពុករបស់ពួកគេ ហើយក៏មិនធ្លាប់មានទំនាស់អ្វីជាមួយគ្នានោះដែរ ដោយខ្លួនមានតួនាទីជាមេភូមិចាវជាអ្នកដឹងខុសត្រូវ ហើយនៅថ្ងៃកើតហេតុខ្លួនបានចូលទៅឃាត់កុំឱ្យវាយគ្នា មិនបានចូលទៅវាយជនរងគ្រោះឱ្យមានរបួសឡើយ ។ នៅថ្ងៃកើតហេតុនិងមានគ្នាពីរក្រុមប៉ុន្តែមិនដឹងអ្នកណាទេ ខាងភូមិខ្លួននិងភូមិល្វា ឈ្លោះគ្នាមកពីនៅក្រៅភូមិទេទាល់តែឈ្លោះគ្នាមកក៏កើតរឿងចូលមកភូមិខ្លួន ដល់តែចូលមកគ្នាច្រើនដល់តែគ្នាច្រើនសន្តិសុខគាត់តេហៅខ្លួនឱ្យមកជួយឃាត់ ។ ទាល់តែពេលខ្លួនមកដល់គេអ្នកឈ្លោះគ្នានឹងគេបែកបាក់គ្នាអស់ហើយ នៅសល់តែអ្នកសួរគ្នាកើតរឿងអី អ្នកណាមកពីណា ខ្លួនសួរទៅមកពីខាងល្វា ឈ្លោះគ្នាជាមួយខាងភូមិខ្លួន ។ នៅពេលដែលខ្លួនមកដល់ខ្លួនចាំមិនអស់ទេ ។ គេប្តឹងខ្លួនថាខ្លួននឹងជិះឡានមកបាំងផ្លូវគេ ។ នៅពេលដែលខ្លួនមកដល់គេបែកគ្នាអស់ហើយ ខ្លួនមកមិនទាន់គេវាយគ្នានោះទេ ។ សំណូមពរក្រុមប្រឹក្សាជំនុំជម្រះមេត្តាឱ្យខ្លួនរួចផុតពីបទចោទប្រកាន់ផង ពីព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។

-ជនជាប់ចោទឈ្មោះ [redacted] បុស្ស បានឆ្លើយថា៖ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ នៅថ្ងៃកើតហេតុនឹងខ្លួនបានឃាត់កុំឱ្យវាយគ្នា ដោយមិនបានចាក់ទៅលើជនរងគ្រោះទេ ។ ខ្លួនមិនស្គាល់ក្រុមដែលវាយគ្នានោះទេព្រោះក្មេងៗ វារាងរញ៉េរញ៉ៃ ដូច្នេះខ្លួនមិនចាំទេ នៅពេលវាយគ្នាគាត់ប្រើប្រាស់ពូថៅ ឯខ្លះប្រើកាំបិត ។ ខ្លួនមានតែដំបងចរាចរណ៍មួយនឹងទេពេលដែលខ្លួនចូលទៅជួយឃាត់ ដំបងចរាចរណ៍នឹងមិនមានចរន្តអគ្គិសនីទេ ។ ជនជាប់ចោទផ្សេងទៀតមិនមានជាប់សាច់ញាតិជាមួយខ្លួនទេ ។ សំណូមពរក្រុមប្រឹក្សាជំនុំជម្រះមេត្តាឱ្យខ្លួនរួចផុតពីបទចោទប្រកាន់ផង ពីព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេខ្លួនមានវ័យចាស់ហើយ ។

-សាក្សីឈ្មោះ [redacted] ឈួន បានឆ្លើយថា៖ ខ្លួនមិនបានចូលមកវាយជាមួយគេនោះទេ ។ ខ្លួនមិនដឹងទេខ្លួនឃើញគេវាយគ្នា ខ្លួនក៏ដើរទៅផ្ទះ ។ ខ្លួនបានឃើញមេភូមិ និងប្រជាការពារភូមិ ពួកគាត់បានចូលទៅជួយឃាត់គេ ។ ខ្លួនមិនបានដឹងថាអ្នកណាវាយជនរងគ្រោះនោះទេ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឈាន បានឆ្លើយថា៖ ដំបូងខ្លួនបានមកពីដើរលេងខ្លួនជិះចូលមកដល់ក៏ឃើញមានឡានរបស់មេភូមិបាំងផ្លូវ ហើយខ្លួនក៏មិនបានដឹងថាមានរឿងហេតុអ្វីដែល ។ ខ្លួនជិះចូលមកខាងភូមិគាត់ក៏បានវាយខ្លួន ។ ហើយពេលរត់ចូលប្រជាការពារភូមិឈ្មោះ [redacted] បុស្ស ជាប្រជាការពារភូមិគាត់ហៅខ្លួនឱ្យចូលហើយគាត់មកចាប់គ្រៀកខ្លួនពីក្រោយ បន្ទាប់មកមានគេមកចាក់ខ្លួនមួយកាំបិតប៉ុន្តែមិនដឹងថាជាអ្នកណាអ្នកចាក់ខ្លួននោះទេព្រោះចាក់ពីក្រោយ ។ ខ្លួនមិនដឹងថាមូលហេតុអ្វីបានជាវាយគ្នានោះទេ នៅពេលដែលខ្លួនជិះចេញពីភូមិនឹងស្ទាក់វាយខ្លួន ហើយមេភូមិក៏នៅ



Scanned with CamScanner

និងដែរហើយមេភូមិហៅខ្លួនឡើងឡានទៅខេត្ត ។ មេភូមិមិនបានវាយខ្លួននោះទេ គ្រាន់តែគាត់បានចាប់ខ្លួន ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ [redacted] រាយ បានឆ្លើយថា៖ ខ្លួនមកពីដើរលេងខ្លួនមិនថាមានរឿងហេតុអ្វីកើតឡើងប៉ុន្តែមិនដឹងក្រុមណានោះទេ ពេលមកដល់ភូមិឃើញមានម៉ូតូមានឡានមួយក្រុម ។ ខ្លួនជិះកាត់មកស្រាប់តែគេដកដំបងមកវាយបងមុនគេព្រោះខ្លួនជិះក្រោយ ។ ខ្លួនឃើញពួកប្រជាការពារភូមិចូលមកវាយបងខ្លួន ខ្លួនរត់ទៅវាលស្រែមានអ្នកតាមវាយខ្លួនទៀតវាយត្រូវដៃនឹងជើង ។ ខ្លួនមិនដែលមានទំនាស់ជាមួយប្រជាការពារភូមិនោះទេ ហើយក៏មិនដែលស្គាល់ពួកគាត់ដែរ ។ ខ្លួនបានឃើញពួកឈ្មោ [redacted] បុស្ស ជាប្រជាការពារភូមិជាអ្នកចាក់បងខ្លួនពីក្រោយមួយកាំបិត ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សេរ៉ា បានឆ្លើយថា៖ ខ្លួនមកពីដើរលេង ខ្លួនមិនបានដឹងថាមានរឿងហេតុអ្វីកើតឡើងនោះទេ មកដល់ភូមិនឹងគេស្ទាក់វាយពួកខ្លួនតែម្តង ។ ប៉ុន្តែមិនដឹងមកពីខាងណាទេ ខ្លួនមិនដឹងថាអ្នកណាវាយខ្លួននោះទេ ។ ចំពោះមេភូមិ និងប្រជាការពារភូមិខ្លួនមិនបានឃើញគាត់ចូលរួមវាយនៅក្នុងរឿងហេតុនឹងទេ ឃើញតែឡានរបស់មេភូមិ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខ្មៅ បានឆ្លើយថា៖ ខ្លួនមកពីដើរលេងខ្លួនមិនដឹងថាមានរឿងអ្វីកើតឡើងនោះទេ មកដល់ភូមិនឹងគេស្ទាក់វាយពួកខ្លួនតែម្តង ។ ប៉ុន្តែមិនដឹងមកពីខាងណាទេ ខ្លួនមិនដឹងថាអ្នកណាវាយខ្លួននោះទេ ។ ខ្លួនមិនចាំនោះទេថាអ្នកណាជាអ្នកចាក់ឈ្មោ [redacted] ឈាន នោះទេ ។ មេភូមិ និងប្រជាការពារភូមិ ខ្លួនមិនបានឃើញគាត់ចូលរួមវាយនៅក្នុងរឿងហេតុនឹងទេ ។

-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិនិត្យពិចារណា និងសម្រេចតាមច្បាប់ ។

-លោកស្រី [redacted] និតិយាំណា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះគឺលោកមេភូមិគាត់បានឆ្លើយថា ពេលដែលចូលទៅដល់គឺក្រុមដែលកំពុងតែប្រតាយប្រតប់គ្នាគឺបានបំបែកគ្នាហើយ ។ ចម្លើយរបស់ជនរងគ្រោះ និងសាក្សីផ្សេងទៀតក៏បានឆ្លើយដូចគ្នាដែរគឺលោកមេភូមិមិនបានចូលរួមនៅក្នុងការវាយគ្នាជាមួយជនរងគ្រោះនោះទេ ។ ដូច្នេះ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០(ក)/១៥ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២២ ដែលសម្រេចឱ្យឈ្មោះ [redacted] ប៊ាន រួចផុតពីបទចោទ ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] បុស្ស គាត់បានឆ្លើយថាគាត់ជាប្រជាការពារភូមិនៅថ្ងៃកើតហេតុគឺគាត់ពុំមានអាវុធនៅក្នុងដៃនោះទេគឺគាត់គ្រាន់តែចូលទៅឃាត់ ឯចម្លើយរបស់ជនរងគ្រោះទាំងពីរនាក់ក៏ឆ្លើយមិនមានភាពច្បាស់លាស់ដែរ ម្តងថាឃើញគាត់រត់ដេញម្តងឃើញថាគាត់អត់គឺរត់ចូលទៅរកគាត់ ។ នេះគឺជាការឆ្លើយចោទប្រកាន់ដោយពុំមានភស្តុតាង ហើយមួយទៀតក្នុងនាមជាជនជាប់ចោទគាត់មានតួនាទីជាប្រជាការពារភូមិច្បាស់ណាស់គឺគាត់មានភារកិច្ចគឺត្រូវការពារដល់ប្រជាជនរបស់គាត់ ។ នៅថ្ងៃ



Scanned with CamScanner

កើតហេតុនឹងគឺមានជម្លោះរវាងក្មេងៗ ឯគាត់ចាស់ហើយដែលឆ្លើយថាគាត់អាយុដល់ជិត៦០ឆ្នាំទៅ ហើយទៅវត់ដេញក្មេងអាយុ២០ឆ្នាំជាង ហើយក្មេងអាយុ២០ឆ្នាំជាងនេះក៏មានកំពស់ខ្ពស់ៗជាងគាត់ដែរ អញ្ចឹងមិនអាចថាគាត់ជាមនុស្សចាស់មួយរូបទៅមានសមត្ថភាពឯណាទៅចាក់ក្មេងដែលពេញកម្លាំង ហើយចាក់ពីក្រោយបែបនេះ ។ ដូចក្រុមប្រឹក្សាបានស្តាប់រួចហើយនៅភាពស៊ីសង្វាក់រវាងចម្លើយរបស់ជនរងគ្រោះទាំងអស់ ។ ដូច្នេះ រឿងនេះក៏ជាវិមតិសង្ស័យដែរស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០(ក)/១៥ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ដែលសម្រេចឱ្យឈ្មោះ [redacted] បុស្ស រួចផុតពីបទចោទ ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿងព្រហ្មទណ្ឌ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង

-ក្រោយពីបានពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍បាត់ដំបង

## យល់ឃើញថា

១-ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ បានប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១០(ក)/១៥ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ត្រង់ចំណុចនៃសេចក្តីសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ាន និងឈ្មោះ [redacted] បុស្ស រួចផុតពីបទចោទប្រកាន់ ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍បាត់ដំបងអាចទទួលជំនុំជម្រះបាន យោងតាមបញ្ញត្តិមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-នាពេលសវនាការនេះជនជាប់ចោទឈ្មោះ [redacted] ប៊ាន បានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ខ្លួនមិនបានស្គាល់ក្មេងរងគ្រោះទាំងអស់នេះទេ ប៉ុន្តែខ្លួនធ្លាប់ស្គាល់ឪពុករបស់ពួកគេ ហើយក៏មិនធ្លាប់មានទំនាស់អ្វីជាមួយគ្នានោះដែរ ដោយខ្លួនមានតួនាទីជាមេភូមិចារជាអ្នកដឹងខុសត្រូវ ហើយនៅថ្ងៃកើតហេតុខ្លួនបានចូលទៅឃាត់កុំឱ្យវាយគ្នា មិនបានចូលទៅវាយជនរងគ្រោះឱ្យមានរបួសឡើយ ។ ចម្លើយនេះអាចឱ្យសាលាឧទ្ធរណ៍ជឿបានថា ជននេះមិនបានចូលរួមប្រើហិង្សាឡើយ ពីព្រោះបើផ្អែកតាមចម្លើយរបស់ជនរងគ្រោះទាំងអស់បានឆ្លើយទៅ



Scanned with CamScanner

សាលាឧទ្ធរណ៍នេះគឺមិនបានឃើញជននេះបានចូលរួមប្រព្រឹត្តអំពើហិង្សាលើជនរងគ្រោះដែរមាន តែការចូលជួយឃាត់ក្នុងនាមជាមេភូមិប៉ុណ្ណោះ ។

៣-នាពេលសវនាការនេះជនជាប់ចោទឈ្មោះ [redacted] បុស្ស បានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ថ្ងៃកើតហេតុខ្លួនពិតជាបានចូលឃាត់កុំឱ្យវាយគ្នា ដោយមិនបានចាក់ទៅលើជនរងគ្រោះទេ ។ ប៉ុន្តែតាមការសួរតទល់នាពេលសវនាការសាលាឧទ្ធរណ៍នេះ របស់គឺជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឈាន បានឆ្លើយបញ្ជាក់ថា នៅយប់កើតហេតុខ្លួនបានរត់ចូលទៅស្នាក់ការប្រជាការពារភូមិឱ្យជួយ តែជនជាប់ចោទឈ្មោះ [redacted] បុស្ស និងមិនបានជួយឡើយ ថែមទាំងបានចាប់ក្រៀកខ្លួនពីក្រោយជាប់ និងមានគេដកកាំបិតមកចាក់ខ្លួន១កាំបិតពីក្រោយបណ្តាលឱ្យមានរបួសធ្ងន់ ដែលចម្លើយរបស់ជនរងគ្រោះនេះមានភាពស៊ីសង្វាក់នឹងចម្លើយរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ឆាយ ដែលបានឆ្លើយនាពេលសវនាការសាលាឧទ្ធរណ៍ថា ខ្លួនបានឃើញជនជាប់ចោទឈ្មោះ [redacted]បុស្ស បានដកកាំបិតចាក់ទៅលើបងប្រុសឈ្មោះ [redacted]ឈាន ប្រាកដមែន ។ ត្រង់ចំណុចនេះចំពោះការឆ្លើយបដិសេធរបស់ជនជាប់ចោទថាមិនបានប្រព្រឹត្តអំពើហិង្សានោះទេ គ្មានភស្តុតាងមកបញ្ជាក់ឡើយ ។ ដូច្នេះ ការដែលសាលាដំបូងខេត្តឧត្តរមានជ័យ ឱ្យជនជាប់ចោទនេះរួចផុតពីបទចោទនោះមិនត្រឹមត្រូវឡើយ ដែលចំណុចនេះត្រូវបានតំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យប្តឹងឧទ្ធរណ៍ប្រយោជន៍ជនរងគ្រោះពិតជាត្រឹមត្រូវ ។

៤-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទដែលបានឆ្លើយគ្រប់ដំណាក់កាលនៃនីតិវិធី ចម្លើយជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឃើញថា ជនជាប់ចោទឈ្មោះ [redacted] ហ៊ាន បានឆ្លើយដោះសារគឺមានភស្តុតាងគ្រប់គ្រាន់ដែលបញ្ជាក់ថា ជនជាប់ចោទគ្មានកំហុសឡើយ ។ ត្រង់នេះឃើញថា គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទនោះទេ ដោយផ្អែកតាមមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌមានខ្លឹមសារជាគោលការណ៍ថា តុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តែទៅលើភស្តុតាងដែលមានក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ ហើយមាត្រា ៣៥៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ថា អង្គហេតុត្រូវច្បាស់លាស់ និងគ្មានការសង្ស័យ ។ ដូច្នេះផ្អែកតាមមាត្រា ៣៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា វិមតិសង្ស័យត្រូវតែបានជាប្រយោជន៍ដល់ជនជាប់ចោទជានិច្ច ។

៥-តំណាងមហាអយ្យការបានសន្និដ្ឋានថា សូមឱ្យក្រុមប្រឹក្សាពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់ ។ សេចក្តីសន្និដ្ឋាននេះសភាព្រហ្មទណ្ឌបានពិចារណា ដូចមានក្នុងសំអាងហេតុខាងលើ ។



Scanned with CamScanner

៦-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានសន្និដ្ឋានថា កូនក្តីខ្លួនបានបដិសេធថាមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ។ ដូច្នេះសូមក្រុមប្រឹក្សាជំនុំជម្រះតម្កល់សាលក្រមរបស់សាលាដំបូងខេត្តសាលាដំបូងខេត្តសៀមរាប និងសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់នេះដដែល ។ សេចក្តីសន្និដ្ឋានឱ្យជនជាប់ចោទរួចខ្លួនពីបទចោទនេះគ្មានអំណះអំណាង និងភស្តុតាងមកបញ្ជាក់គ្រប់គ្រាន់ដែលអាចឱ្យសភាព្រហ្មទណ្ឌលើកយកមកពិចារណា និងសម្រេចបានឡើយចំពោះជនជាប់ចោទឈ្មោះ [redacted] ប៊ុស្ស ។ ចំពោះសេចក្តីសន្និដ្ឋានសុំឱ្យរួចខ្លួនលើជនជាប់ចោទឈ្មោះ [redacted] ហ៊ាន គឺសាលាឧទ្ធរណ៍បានពិចារណាដូចការយល់ឃើញខាងលើ ។

៧-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុស្ស បានសំណូមពរថា សូមសម្រេចឱ្យខ្លួនរួចផុតពីបទចោទ ។ ចំពោះសំណូមពរនេះ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ពុំអាចលើកយកមកពិចារណាបានទេ ។

៨-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ាន បានសំណូមពរថា សូមសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល ។ ចំពោះសំណូមពរនេះសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍អាចលើកយកមកពិចារណា និងសម្រេចបាន ដូចការយល់ឃើញខាងលើ ។

៩-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ប៊ុស្ស ភេទប្រុស អាយុ៥៦ឆ្នាំ ដែលមានសាវតាជាតិដូចខាងលើ ពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិចារថ្មី ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

១០-គ្មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ហ៊ាន ភេទប្រុស អាយុ៥៥ឆ្នាំ ដែលមានសាវតាជាតិដូចខាងលើ ពីបទ៖ ប៉ុនប៉ងឃាតកម្ម និងហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិចារថ្មី ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៩៩ និងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

១១-រឿងក្តីនេះបានបង្កឡើងដោយមានភាគីទាំងសងខាង បានវាយគ្នាជាក្រុមទៅវិញទៅមក ដោយមានបក្សពួករៀងៗខ្លួន ដូច្នេះជាកំហុសរបស់ជនរងគ្រោះមួយផ្នែកដែរ ។ ចំពោះស្ថានភាពជនជាប់ចោទឈ្មោះ [redacted] ប៊ុស្ស មិនចេះអក្សរឡើយ ដែលនាំឱ្យជននេះខ្វះការពិចារណា ទើបប្រព្រឹត្តបទល្មើសជាលើកដំបូងនេះ ។ ម្យ៉ាងទៀតស្ថានភាពគ្រួសារមានជីវភាពក្រីក្រមានកូនចំនួន៥នាក់ ក្នុងបន្ទុក ។ ដូច្នេះគប្បីព្យួរការអនុវត្តទោសមួយផ្នែកដល់ជនជាប់ចោទយោងតាមមាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ដើម្បីឱ្យជននេះកែប្រែខ្លួនចូលទៅរួមរស់ក្នុងសង្គមវិញ ។

១២-ក្នុងរឿងក្តីនេះជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ឃាន មិនបានទាមទារសំណងពីជនជាប់ចោទឈ្មោះ [redacted] បុស្ស ឡើយ ដូច្នេះសាលាឧទ្ធរណ៍មិនលើកយកមកពិចារណាទេ ។

១៣-បណ្តឹងឧទ្ធរណ៍របស់តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ ចំពោះជនជាប់ចោទឈ្មោះ [redacted]បុស្ស ធ្វើឡើងមានមូលហេតុសមស្របតាមនីតិវិធីច្បាប់ ដែលគប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ទទួលយកមកពិចារណា ។ ចំពោះបណ្តឹងឧទ្ធរណ៍លើជនជាប់ចោទឈ្មោះ [redacted]ប៊ិាន ធ្វើឡើងពុំមានមូលហេតុស្របតាមនីតិវិធីច្បាប់ឡើយ ដែលគប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បដិសេធចោល ហើយតម្កល់សេចក្តីសម្រេចរបស់សាលាដំបូងខេត្តឧត្តរមានជ័យទុកជាបានការដដែល ។

១៤-សាលក្រមព្រហ្មទណ្ឌលេខ ១០(ក)/១៥ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវខ្លះ និងមិនត្រឹមត្រូវខ្លះ គប្បីតម្កល់ទុកផ្នែកខ្លះ និងបដិសេធផ្នែកខ្លះ ដូចការយល់ឃើញខាងលើ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលផ្នែកខ្លះនៃពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០(ក)/១៥ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ត្រង់សេចក្តីសម្រេចចំណុច ១ ដែលឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ិាន រួចផុតពីការចោទប្រកាន់ ទុកជាបានការដដែល ។ ចំពោះសេចក្តីសម្រេចចំណុច ១ ដែលឱ្យជនជាប់ចោទឈ្មោ[redacted]បុស្ស រួចផុតពីការចោទប្រកាន់ត្រូវបដិសេធចោល ហើយសម្រេចដូចខាងក្រោម៖

ផ្តន្ទាទោសជនជាប់ចោទឈ្មោ[redacted] បុស្ស ភេទប្រុស អាយុ៥៥ឆ្នាំ ដែលមានសារធាតុដូចខាងលើដាក់ពន្ធនាគារកំណត់ ២(ពីរ)ឆ្នាំ និង៦(ប្រាំមួយ)ខែ តែទោសនេះអនុវត្តក្នុងពន្ធនាគារកំណត់ ១(មួយ)ឆ្នាំ ហើយទោសដែលសល់ត្រូវព្យួរការអនុវត្តធម្មតា ពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិចារថ្មី ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១០៧ មាត្រា ១០៨ និងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ និងប្រកាសជាសា



Scanned with CamScanner

ពារណៈនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហ៊ាន និងឈ្មោះ យ៉េន បុស្ស និងចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]ហាន, ឈ្មោ[redacted] គាយ; ឈ្មោះ [redacted] សេរ៉ា និងឈ្មោះ [redacted] ។

រក្សាសិទ្ធិប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] | [redacted] |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៤កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

សាលាឧទ្ធរណ៍ភ្នំពេញ, ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២

| បានឃើញ<br>ប្រធានក្រុមប្រឹក្សាជំនុំជម្រះ | ក្រឡាបញ្ជី |
|---|---|
| [redacted] | [redacted] |



Scanned with CamScanner